អាជ្ញាធរអគ្គិសនីកម្ពុជា
Electricity Authority of Cambodia

ឆ្នាំទី២ លេខ ០០៦
ចេញផ្សាយសម្រាប់
ខែកក្កដា-កញ្ញា ឆ្នាំ២០១៥

លេខៈ ០០៦

ព្រឹត្តិបត្រ

# ព័ត៌មានអគ្គិសនី



ឯកឧត្តម បណ្ឌិត ទី នរិទ្ធ ប្រធានEAC អញ្ជើញចូលរួមជាអធិបតីបើកសិក្ខាសាលាស្តីពីការផ្លាស់ប្តូរយោបល់អំពីបទដ្ឋានក្នុងការអនុវត្តន៍ និងការត្រួតពិនិត្យលើការផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារអ៊ិនធើកង់ទីណង់តាល់ (សូមអានទំព័រទី ២០)



ដំណើរទស្សនកិច្ចរបស់គណៈប្រតិភូសមាគមបញ្ញត្តិករអគ្គិសនីសហរដ្ឋអាមេរិក មកកាន់ទីស្នាក់ការអាជ្ញាធរអគ្គិសនីកម្ពុជា
(សូមអានទំព័រទី ២០)



កិច្ចប្រជុំពិភាក្សាការងារជាមួយក្រសួងថាមពល និងរ៉ែប្រទេសឡាវ
(សូមអានទំព័រទី ១៩)



# តួនាទី និងភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ១.តួនាទីរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

មាត្រា៦ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា «អាជ្ញាធរអគ្គិសនីកម្ពុជាគឺជានីតិបុគ្គលនៃនីតិសាធារណៈដែលទទួលនូវសិទ្ធិពីរាជរដ្ឋាភិបាល និងមានស្វ័យភាពក្នុងការត្រួតពិនិត្យលើការផ្ញើសេវាកម្មអគ្គិសនី និងគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី ។ មានន័យថា អាជ្ញាធរអគ្គិសនីកម្ពុជា គឺជាស្ថាប័នបម្រើកិច្ចការសាធារណៈមួយក្នុងវិស័យអគ្គិសនី ដែលរាជរដ្ឋាភិបាលបានប្រគល់សិទ្ធិ និងស្វ័យភាពឲ្យត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី។ យោងតាមការកំណត់របស់ច្បាប់ខាងលើ រាជរដ្ឋាភិបាលបានផ្តល់នូវសិទ្ធិ និងស្វ័យភាពឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចំនួន២ចំណុចគឺៈ ទី១-ត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងទី២-គ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី ។

## ២.ភារកិច្ចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

មាត្រា៧ នៃច្បាប់ស្តីពីអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវភារកិច្ចចំនួន១៥ ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអនុវត្ត ដើម្បីធានាឲ្យការផ្តល់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តទៅដោយ ប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាព ។ ភារកិច្ចទាំង១៥ ដែលច្បាប់បានកំណត់ក្នុងមាត្រាទី៧ នេះ គឺជាសិទ្ធិអំណាចដែលច្បាប់បានប្រគល់ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជា ដូចខាងក្រោមៈ

1. ចេញ កែសម្រួល ព្យួរ ដកហូត ឬបដិសេធ អាជ្ញាបណ្ណសម្រាប់ការផ្គត់ផ្គង់សេវាកម្មអគ្គិសនី ។
2. អនុម័តថ្លៃ និងបន្ទុកចំណាយផ្សេងៗ ព្រមទាំងលក្ខខណ្ឌនៃសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាបណ្ណ ។ លើកលែងតែថ្លៃ និងបន្ទុកផ្សេងៗ ព្រមទាំងលក្ខខណ្ឌទាំងនោះ ត្រូវបានបង្កើតឡើងតាមវិធីប្រកួតប្រជែង និងផ្អែកលើទីផ្សារ ។
3. កំណត់ឲ្យអនុវត្តបញ្ញត្តិ បែបបទ និងស្តង់ដា សម្រាប់កម្មវិធីវិនិយោគរបស់អ្នកកាន់អាជ្ញាបណ្ណ ។
4. ពិនិត្យឡើងវិញលើសកម្មភាពហិរញ្ញវត្ថុ និងរចនាសម្ព័ន្ធសហគ្រាសរបស់អ្នកកាន់អាជ្ញាបណ្ណកម្រិតមួយ ដែលអាចជាឧបសគ្គដោយផ្ទាល់ដល់កិច្ចប្រតិបត្តិការនៃវិស័យអគ្គិសនី និងប្រសិទ្ធភាពនៃការផ្គត់ផ្គង់អគ្គិសនី ។
5. អនុម័ត និងដាក់ឲ្យអនុវត្តស្តង់ដាប្រតិបត្តិសម្រាប់អ្នកកាន់អាជ្ញាបណ្ណ ។
6. វាយតម្លៃ និងសម្រុះសម្រួលបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ និងវិវាទកិច្ចសន្យាដែលពាក់ព័ន្ធនឹងអ្នកកាន់អាជ្ញាបណ្ណ ។ ក្នុងករណីដែលការតវ៉ា និងវិវាទនោះទាក់ទិននឹងការរំលោភបំពានលើលក្ខខណ្ឌដែលមានកំណត់ក្នុងអាជ្ញាបណ្ណ ។
7. អនុម័ត និងដាក់ឲ្យប្រតិបត្តិនូវប្រព័ន្ធគណនីឯកភាពសម្រាប់អ្នកកាន់អាជ្ញាបណ្ណទាំងអស់ ។
8. រៀបចំ និងផ្សព្វផ្សាយរបាយការណ៍លើវិស័យអគ្គិសនី និងព័ត៌មានពាក់ព័ន្ធនានាដែលទទួលពីអ្នកកាន់អាជ្ញាបណ្ណសម្រាប់ផលប្រយោជន៍ដល់រាជរដ្ឋាភិបាល និងប្រយោជន៍សាធារណៈ ។
9. កំណត់កម្រៃនានា ដែលត្រូវអនុវត្តលើអ្នកកាន់អាជ្ញាបណ្ណ ។
10. កំណត់បែបបទសម្រាប់ការផ្តល់ព័ត៌មានដល់សាធារណជន អំពីកិច្ចការក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាអនុវត្ត ទៅតាមគោលការណ៍តម្លាភាព ដូចមានចែងក្នុងមាត្រា៣ នៃច្បាប់នេះ ។
11. ចេញបញ្ញត្តិ និងបទបញ្ជាសមស្របព្រមទាំងបញ្ជាផ្អាកជាបណ្តោះអាសន្ន និងជាស្ថាពរចំពោះសេវាករអគ្គិសនី ។
12. ពិន័យជាប្រាក់ ផ្អាកការប្រើប្រាស់អគ្គិសនី ព្យួរ ឬដកហូតអាជ្ញាបណ្ណ ចំពោះករណីរំលោភលើច្បាប់ និងលិខិតបទដ្ឋាននានាព្រមទាំងបញ្ញត្តិផ្សេងៗទៀត របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។
13. តម្រូវឲ្យអ្នកធ្វើសេវាកម្ម និងអ្នកប្រើប្រាស់អគ្គិសនីគោរពប្រតិបត្តិ នូវរាល់វិធានដែលទាក់ទងនឹងសន្តិសុខ ថាមពល សេដ្ឋកិច្ច បរិស្ថានរបស់ប្រទេសជាតិ ព្រមទាំងគោលនយោបាយដទៃទៀតរបស់រាជរដ្ឋាភិបាល ។
14. ចាត់វិធានការផ្សេងទៀតចំពោះបញ្ហាបន្ទាប់បន្សំ ឬជាផលវិបាកស្តែងចេញពីមុខងារដូចបានរៀបរាប់ខាងលើនេះ ។
15. បង្កើតលក្ខខណ្ឌជ្រើសរើស និងប្រើប្រាស់មន្ត្រី ឬបុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងជំនាញការ ឬទីប្រឹក្សា ៕

# សារពីឯកឧត្តមប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា



ឯកឧត្តម បណ្ឌិត ទី នរិន្ទ

ព្រឹត្តិបត្រព័ត៌មានអគ្គិសនីនេះត្រូវបានរៀបចំ និងបោះពុម្ពផ្សាយដោយអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងគោលបំណងផ្សព្វផ្សាយពីព្រឹត្តិការណ៍ថ្មីៗទាក់ទងនឹងវិស័យអគ្គិសនី ក៏ដូចជាសកម្មភាពសំខាន់ៗរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការបំពេញនូវតួនាទីបញ្ញត្តិ និងត្រួតពិនិត្យចំពោះការផ្តល់សេវាកម្មអគ្គិសនីទូទាំងប្រទេសជូនដល់រាជរដ្ឋាភិបាល ស្ថាប័ននានា អ្នកវិនិយោគ និងសាធារណជន ដែលមានបំណងចង់ដឹងពីស្ថានភាពរបស់វិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដោយសារមានការសាងសង់ប្រព័ន្ធបញ្ជូនរងតង់ស្យុងមធ្យម អ្នកកាន់អាជ្ញាបណ្ណកាន់តែច្រើនឡើងកំពុងភ្ជាប់ជាមួយប្រព័ន្ធនេះ។ ជាលទ្ធផលមានអ្នកប្រើប្រាស់កាន់តែច្រើន ទទួលបានថ្លៃអគ្គិសនីកាន់តែទាប ហើយគុណភាពនៃការផ្គត់ផ្គង់កាន់តែប្រសើរឡើង ។

ជាក់ស្តែងគិតត្រឹមត្រីមាសទី២ ឆ្នាំ២០១៥ មានអ្នកប្រើប្រាស់បានកើនឡើងដល់ចំនួន១,៤៨៩,៥១១ ខ្នងផ្ទះបានភ្ជាប់ចរន្តជាមួយបណ្តាញអគ្គិសនីរួចហើយ ។ ដោយកំណើននៃអ្នកប្រើប្រាស់បានកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ យើងសង្កេតឃើញថា បញ្ហាវិវាទរវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ ជារឿយៗបានកើតមានជាញឹកញាប់ដោយសារតែអ្នកផ្គត់ផ្គង់មួយចំនួនបានឆ្លៀតឱកាស ពេលដែលអ្នកប្រើប្រាស់មិនទាន់បានយល់ដឹងពីច្បាប់និងបទប្បញ្ញត្តិដើម្បីបង្កើនភាពយុត្តិធម៌និងសមធម៌ក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនី បានអនុវត្តខុសពីសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដូចជា ៖

១.ការយកថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ខុសពីសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

២.អនុវត្តថ្លៃលក់ខុស ឬកេងយកចំណេញដោយអនុវត្តថ្លៃខ្ពស់នៅតំបន់ឆ្ងាយៗ

៣.ការដាក់នាឡិកាស្ទង់ឲ្យធំដើម្បីយកថ្លៃភ្ជាប់ចរន្ត និងប្រាក់កក់ឲ្យបានច្រើន

៤.ការមិនចេញឯកសារទទួលប្រាក់កក់ឲ្យអ្នកភ្ជាប់ចរន្ត ឬចេញឲ្យដែរតែមិនត្រឹមត្រូវជាដើម ។

យ៉ាងណាមិញ បញ្ហាវិវាទទាំងអស់មិនមែនសុទ្ធតែបង្កដោយអ្នកផ្គត់ផ្គង់ ដោយសារតែបញ្ហាខ្វះការយល់ដឹងរបស់អ្នកប្រើប្រាស់ខាងលើនោះទេ ជួនកាលអ្នកប្រើប្រាស់ក៏បានធ្វើសំណូមពរ និងទាមទារលើសពីអ្វីដែលបានកំណត់ក្នុងច្បាប់ និងលក្ខខណ្ឌដែរ ដូចជា ៖

១.ការទាមទារឲ្យតម្លៃអគ្គិសនីចុះទាបជាងថ្លៃដើម ដែលធ្វើឲ្យអ្នកផ្គត់ផ្គង់មិនអាចដំណើរការអាជីវកម្មបាន

២.ការតវ៉ាពីបញ្ហាថ្លៃអគ្គិសនីខុសគ្នារវាងតំបន់អ្នកកាន់អាជ្ញាបណ្ណមួយទៅអ្នកកាន់អាជ្ញាបណ្ណមួយទៀតដែលនៅក្បែរគ្នា និងបញ្ហាមិនប្រក្រតីក្នុងការប្រើប្រាស់ដោយកំហុសបច្ចេកទេសរបស់អ្នកប្រើប្រាស់ខ្លួនឯងជាដើម។

ឆ្លងតាមព្រឹត្តិបត្រព័ត៌មាននេះ អាជ្ញាធរអគ្គិសនីកម្ពុជាសង្ឃឹមថានឹងអាចផ្តល់ព័ត៌មានអំពីសកម្មភាព និងដំណើរការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ក៏ដូចជាចំណេះដឹងស្តីពីច្បាប់ និងបទប្បញ្ញត្តិដល់មិត្តអ្នកអានទាំងអស់ដើម្បីឲ្យការផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ប្រកបដោយតម្លាភាព យុត្តិធម៌ និងសមធម៌ ៕

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

ព្រឹត្តិបត្រព័ត៌មានអគ្គិសនី

# មាតិកា

លេខ០០៦

## សម័យប្រជុំ

-សម័យប្រជុំលើកទី ២៨០................................ទំព័រ ០១
-សម័យប្រជុំលើកទី ២៨១................................ទំព័រ ០២
-សម័យប្រជុំលើកទី ២៨២................................ទំព័រ ០៤
-សម័យប្រជុំលើកទី ២៨៣................................ទំព័រ ០៦
-សម័យប្រជុំលើកទី ២៨៤................................ទំព័រ ០៨
-សម័យប្រជុំលើកទី ២៨៦................................ទំព័រ ០៩

## ព័ត៌មានសំខាន់ៗ

-ការចុះត្រួតពិនិត្យនាឡិកាស្ទង់ក្រុមហ៊ុន ភី អេស ស៊ី អិនវេសមេន និងការធ្វើសេវាកម្មរបស់សេវាករ ហ៊ុយ ចេង...ទំព័រ ១១

-មន្ត្រីជំនាញអាជ្ញាធរអគ្គិសនីកម្ពុជា ចុះពិនិត្យការធ្វើសេវាកម្មអគ្គិសនីរបស់សេវាករមួយចំនួន នៅខេត្តកំពង់ធំ និងខេត្តសៀមរាប................................ទំព័រ ១៣

-ការចុះត្រួតពិនិត្យការធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនិងថ្លៃសេវាកម្មពាក់ព័ន្ធរបស់ ក្រុមហ៊ុន ផេង គៀង អេឡិកទ្រីស៊ីធី សេវាករ ង៉ិន គង់ និងសេវាករ គឹម ច័ន្ទតារា...........ទំព័រ ១៥

-ការចុះពិនិត្យការធ្វើសេវាកម្មអគ្គិសនី និងដោះស្រាយការតវ៉ារបស់ប្រជាពលរដ្ឋចំពោះក្រុមហ៊ុន សុខា អេឡិកទ្រីស៊ីធី នៅឃុំពោធិម្រាល ស្រុកបសេដ្ឋ ខេត្តកំពង់ស្ពឺ.............ទំព័រ ១៧

-កិច្ចប្រជុំពិភាក្សាផ្លាស់ប្តូរបទពិសោធន៍ការងារ រវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងក្រសួងថាមពល និងរ៉ែឡាវ.........ទំព័រ១៩

-សិក្ខាសាលាស្តីពីកិច្ចសហប្រតិបត្តិការ រវាងអាជ្ញាធរអគ្គិសនីកម្ពុជា EAC ជាមួយសមាគមបញ្ញត្តិករជាតិសហរដ្ឋអាមេរិក NARUC នៅសណ្ឋាគារអ៊ិនធើកង់ទីណង់តាល់.........ទំព័រ ២០

-កិច្ចប្រជុំពិគ្រោះយោបល់ពីភាពមិនប្រក្រតី នៃការតភ្ជាប់បណ្តាញអគ្គិសនីឲ្យអ្នកប្រើប្រាស់នៅស្រុកពួក ខេត្តសៀមរាប ........................................ទំព័រ ២២

-ការចុះពិនិត្យការធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីរបស់សេវាករនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង និងដោះស្រាយពាក្យបណ្តឹងតវ៉ាចំពោះសេវាករ ង៉ិន គង់ នៅស្រុកបារាយណ៍ ខេត្តកំពង់ធំ ........................................ទំព័រ ២៣

-ការចុះពិនិត្យដោះស្រាយ បញ្ហាក្នុងការធ្វើសេវាកម្មអគ្គិសនីរបស់សេវាករ ធូក សាមាន នៅឃុំស្វាយជ្រុំ ស្រុកមេសាង ខេត្តព្រៃវែង........................................ទំព័រ ២៥

## ច្បាប់ និងបញ្ញត្តិកម្មអគ្គិសនី

-ជំពូកទី៥ «ប្រភេទអាជ្ញាបណ្ណ» នៃច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា........................................ទំព័រ ២៥